# អគ្គិសនីកម្ពុជា

# ELECTRICITE DU CAMBODGE

# របាយការណ៍ប្រចាំឆ្នាំ ២០១៤



# សេចក្តីថ្លែងការណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល



តាងនាមឲ្យក្រុមប្រឹក្សាភិបាល ខ្ញុំសូមសំដែងនូវការកោតសរសើរយ៉ាងស្មោះចំពោះ អគ្គិសនីកម្ពុជា ដែលបានបញ្ចេញនូវរបាយការណ៍ប្រចាំឆ្នាំ ២០១៤ ។ យើងមាន មោទនភាពចំពោះលទ្ធផល ដែលអគ្គិសនីកម្ពុជាសម្រេចបានអំឡុងឆ្នាំ ២០១៤ និង ជឿជាក់យ៉ាងខ្លាំងថា អគ្គិសនីកម្ពុជានឹងឈានឆ្ពោះទៅកាន់ការសម្រេចបាននូវគោលដៅ និងចក្ខុវិស័យរបស់ខ្លួន ក្នុងគោលបំណង ដើម្បីឲ្យក្លាយជាក្រុមហ៊ុនឈានមុខគេលើវិស័យថាមពលនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដោយកសាងទំនាក់ទំនង និងសេវាកម្មល្អ ប្រកបដោយទំនុកចិត្ត ក្នុងការផ្គត់ផ្គង់ អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងតម្លៃសមរម្យជូនអតិថិជនរបស់ខ្លួន។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល ខ្ញុំមានសេចក្តីពេញចិត្តយ៉ាងខ្លាំង ចំពោះភាពជោគជ័យដ៏ធំធេងដែលនិយោជិត និយោជក របស់អគ្គិសនីកម្ពុជាសម្រេចបានក្នុងឆ្នាំកន្លងមក។ សមិទ្ធផលមានជាបន្តបន្ទាប់ប៉ុន្មានឆ្នាំកន្លងមកនេះ គឺជាសមិទ្ធផលដែលមិនធ្លាប់មានពីមុនមក។

ក្នុងឱកាសនេះ ខ្ញុំសូមសំដែងនូវអំណរគុណអស់ពីដួងចិត្តខ្ញុំផ្ទាល់ ចំពោះថ្នាក់ដឹកនាំ និងនិយោជិតអគ្គិសនីកម្ពុជាទាំងអស់ ដែលបានបំពេញការងារអស់ពីកម្លាំងកាយ និងកម្លាំងបញ្ញាស្មារតី ដែលធ្វើឲ្យសម្រេចបាននូវសមិទ្ធផលជាច្រើនកន្លងមក ដើម្បីឈានដល់ទិសដៅ និងចក្ខុវិស័យរបស់ខ្លួន។

**ប្រធានក្រុមប្រឹក្សាភិបាល**



**វិចធ័រ ហ្សូនា**

## ពីប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា



ខ្ញុំមានមោទនភាព និងសូមបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០១៤ ដែលអគ្គិសនីកម្ពុជាទទួលបាន ដោយផ្អែកលើចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា គឺធ្វើយ៉ាងណាឲ្យក្លាយជាអង្គភាពអគ្គិសនីឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវខិតខំយ៉ាងខ្លាំងក្នុងការបំពេញតម្រូវការប្រើប្រាស់ថាមពលអគ្គិសនី និងធ្វើឲ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃការផ្គត់ផ្គង់ជូនអតិថិជន។

ក្នុងឆ្នាំ២០១៤ ការលក់ថាមពលអគ្គិសនីរបស់អគ្គិសនីកម្ពុជា បានកើនឡើងដល់ ៤.១៥១,៧៣ ជីហ្គាវ៉ាត់ម៉ោង (GWh) ឬ ១៩,១៨% ច្រើនជាងឆ្នាំមុន ទន្ទឹមនឹងនោះ ការបាត់បង់លើប្រព័ន្ធទាំងមូល មានកម្រិតត្រឹម ៨%។ ចំណូលប្រចាំឆ្នាំមានការកើនឡើងដល់ ៣.០១៣ ប៊ីលានរៀល ឬ ១៣% ច្រើនជាងឆ្នាំមុន។ យើងមាននិយោជិតសរុបចំនួន ៣.៥៨៥ នាក់ សម្រាប់បម្រើសេវាកម្មជូនអតិថិជនចំនួន ៥៤១.១៤១។

អំឡុងឆ្នាំ ២០១៤ រោងចក្រវារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម ៣៣៨ មេហ្គាវ៉ាត់(MW) រោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម ១៣៥ មេហ្គាវ៉ាត់(MW) ម៉ាស៊ីនទី១ នៃអានុភាពតម្លើងសរុប ២៧០ មេហ្គាវ៉ាត់(MW) និងរោងចក្រវារីអគ្គិសនីស្ទឹងតាតៃ ២៤៦ មេហ្គាវ៉ាត់(MW) ត្រូវបានសាងសង់រួចជាស្ថាពរ និងដាក់ឲ្យដំណើរការដោយបានតភ្ជាប់ និងផ្គត់ផ្គង់ថាមពលទៅបណ្តាញជាតិតាមរយៈខ្សែបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុល(kV) កាត់តាមអនុស្ថានីយអូរសោម និងអនុស្ថានីយស្ទឹងហាវ មករាជធានីភ្នំពេញ។ ទន្ទឹមនឹងនោះ ថាមពលនាំចូលពីប្រទេសវៀតណាមតាមរយៈខ្សែបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុល(kV) ក៏ត្រូវបានឯកភាពឲ្យកើនឡើងដល់ ២០០ មេហ្គាវ៉ាត់(MW) ផងដែរ ដើម្បីធានាដល់កំណើននៃការប្រើប្រាស់ ។

ខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល(kV) ពីអនុស្ថានីយស្ទឹងហាវ ទៅអនុស្ថានីយខេត្តព្រះសីហនុ ស្ថិតក្រោមប្រាក់កម្ចី ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) មានប្រវែង ១១ គីឡូម៉ែត្រ(km) និងខ្សែបញ្ជូនតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល(kV) មួយខ្សែទៀតពីអនុស្ថានីយឈូក ទៅអនុស្ថានីយបន្ទាយមាស ក្រោមថវិការបស់អគ្គិសនីកម្ពុជា ដែលមានប្រវែង ១២ គីឡូម៉ែត្រ(km) ត្រូវបានដាក់ឲ្យដំណើរការ។

គម្រោងអគ្គិសនីភាវូបនីយកម្មជនបទ ដែលស្ថិតក្រោមប្រាក់កម្ចីរបស់ធនាគារចិនអ៊ិចស៊ីម (China Exim Bank) កំពុងដំណើរការសាងសង់ប្រព័ន្ធចែកចាយតង់ស្យុងមធ្យម ដែលគ្របដណ្តប់ខេត្តចំនួន ០៤ ដូចជា ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដែលមានប្រវែងសរុប ២.០០០ km ។

បន្ថែមពីនេះ គម្រោងអគ្គិសនីភាវូបនីយកម្មជនបទដំណាក់កាលទី២ ស្ថិតក្រោមមូលនិធិរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលគ្របដណ្តប់ខេត្តចំនួន ៦ ដូចជា ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប ដែលមានប្រវែងសរុបប្រមាណ ១.២០០ គីឡូម៉ែត្រ(km) បានចាប់ផ្តើមសាងសង់ ហើយរំពឹងថារួចរាល់ជាស្ថាពរនៅឆ្នាំ ២០១៦។ ខ្សែបណ្តាញចែកចាយប្រវែង ២.០៤០ គីឡូម៉ែត្រ(km) និងខ្សែបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ប្រវែង ២២០ គីឡូម៉ែត្រ(km) ត្រូវបានស្នើសុំជំនួយហិរញ្ញវត្ថុពីធនាគារចិនអ៊ិចស៊ីម (China Exim Bank) ដំណាក់កាលទី២, ៣ និង ៤ ជាបន្តបន្ទាប់ ដែលគ្របដណ្តប់ខេត្តចំនួន ១៤ ដូចជា ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តកោះកុង និងខេត្តព្រះសីហនុ។

លើសពីនេះទៅទៀត បណ្តាអ្នកកាន់អាជ្ញាប័ណ្ណ (សេវាករ) បម្រើសេវាចែកចាយអគ្គិសនីចំនួន ១២៣ បានចុះកិច្ចព្រមព្រៀងលក់-ទិញថាមពលអគ្គិសនីជាមួយអគ្គិសនីកម្ពុជា ដោយភ្ជាប់ជាមួយបណ្តាញរបស់អគ្គិសនីកម្ពុជា ដើម្បីផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់អាជ្ញាប័ណ្ណរបស់ខ្លួន ដោយបានបញ្ឈប់ឲ្យដំណើរការនូវម៉ាស៊ីនភ្លើងតូចៗ របស់ខ្លួន ដែលជាប្រភពប្រើប្រាស់ប្រេងមានតម្លៃខ្ពស់។

នៅក្នុងឆ្នាំនេះដែរ អគ្គិសនីកម្ពុជាបានផ្តល់ជំនួយឥតសំណងចំនួន ៦ លានដុល្លារអាមេរិក ទៅកាន់នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ដើម្បីបន្តការជំរុញ និងអភិវឌ្ឍន៍វិស័យអគ្គិសនីភាវូបនីយកម្មជនបទទូទាំងប្រទេស តាមរយៈគោលនយោបាយឧបត្ថម្ភធនរបស់អគ្គិសនីកម្ពុជា។

លទ្ធផលនៃកិច្ចខំប្រឹងប្រែងខាងលើ បានផ្តល់នូវប្រយោជន៍ដោយផ្ទាល់ និងដោយប្រយោលជាច្រើនជូនដល់ប្រជាជនរាប់សែនគ្រួសារ រួមទាំងការទាក់ទាញការវិនិយោគនៅទូទាំងប្រទេស ដែលប្រការទាំងនេះបានឆ្លុះបញ្ចាំងឲ្យឃើញពីភាពរឹងមាំ និងការរីកចម្រើនឥតឈប់ឈរ ក្នុងការរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជា ដើម្បីស្ថាបនាបាននូវគ្រឹះដ៏រឹងមាំ សម្រាប់កិច្ចអភិវឌ្ឍន៍ឲ្យមាននិរន្តភាពសេដ្ឋកិច្ច និងសង្គមជាតិ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមធ្វើការកត់សម្គាល់ពីការចូលរួមចំណែក និងការប្តេជ្ញាចិត្តដ៏មុះមុតរបស់និយោជិតយើងទាំងអស់គ្នា ដែលបានដើរតួនាទីដ៏សំខាន់ និងមិនអាចខ្វះបានក្នុងការសម្រេចបានជោគជ័យជូនអង្គភាពនេះ។ យើងខ្ញុំសូមសម្តែងនូវកតញ្ញូដ៏ជ្រាលជ្រៅ ចំពោះការណែនាំដ៏មានសារៈសំខាន់ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលសម្តេចតែងផ្តល់ការគាំទ្រជាគន្លឹះៗ នៅគ្រប់របត់សំខាន់ៗ ទាំងអស់។

យើងខ្ញុំសូមសម្តែងនូវការដឹងគុណ ចំពោះក្រសួង រ៉ែ និង ថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានបន្តចង្អុលបង្ហាញទិសដៅ និងគាំទ្រយ៉ាងខ្លាំងក្លា ។ យើងខ្ញុំសូមសំដែងនូវសេចក្តីសោមនស្សរីករាយជាពិសេសជូនដល់អាជ្ញាធរអគ្គិសនីកម្ពុជា និងចំពោះសមាជិកក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា សម្រាប់ការចូលរួមចំណែក ការគាំទ្រ និងការណែនាំកន្លងមក ។ យើងខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ផងដែរ ចំពោះការគាំទ្រពីសំណាក់អតិថិជនគ្រប់ប្រភេទរបស់អគ្គិសនីកម្ពុជា ជាងនេះទៅទៀត យើងខ្ញុំសូមសម្តែងនូវការកោតសរសើរ ចំពោះដៃគូអភិវឌ្ឍន៍នានា និងដៃគូអ្នកផលិតថាមពលឯករាជ្យទាំងអស់ ក្នុងការជួយជ្រោមជ្រែង និងសហការគ្នាយ៉ាងជិតស្និទ្ធជាបន្តបន្ទាប់ ។

ដោយទទួលបានសមិទ្ធផល និងការលើកទឹកចិត្តទាំងនេះ យើងខ្ញុំបានត្រៀមខ្លួន ដើម្បីដឹកនាំអគ្គិសនីកម្ពុជា និងវិស័យថាមពល ឲ្យមានការអភិវឌ្ឍន៍ឈានដល់កម្រិតអតិបរមា ។ យើងខ្ញុំមានសង្ឃឹមដ៏មុតមាំថានាថ្ងៃអនាគត វិស័យថាមពល នឹងមានសន្ទុះដ៏ប្រសើរបំផុត។

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**
**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កែវ រតនៈ**

## ចក្ខុវិស័យ

ចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា គឺធ្វើយ៉ាងណាឲ្យក្លាយជាអង្គភាពអគ្គិសនី ឈានមុខគេនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយត្រូវខិតខំយ៉ាងខ្លាំង ក្នុងការបំពេញតម្រូវការប្រើប្រាស់ថាមពលអគ្គិសនី និងធ្វើឲ្យប្រសើរឡើងនូវគុណភាព និងប្រសិទ្ធភាពនៃការផ្គត់ផ្គង់ថាមពលអគ្គិសនីជូនអតិថិជន។

## ទស្សនវិស័យ

ផ្តល់ការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ ប្រកបដោយ ស្ថេរភាព គុណភាព ប្រសិទ្ធភាព ជូនអតិថិជននៅក្នុងតំបន់ដែលមានអាជ្ញាប័ណ្ណរបស់ខ្លួន ដោយតម្លៃប្រកួតប្រជែង។ បង្កើនប្រតិបត្តិការអាជីវកម្មឲ្យបានប្រសើរបំផុត និងប្រកបដោយប្រសិទ្ធភាព និងឧត្តមភាព និងចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីកាត់បន្ថយភាពក្រីក្រ ការពារបរិស្ថាន និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។

## តួនាទី និងការទទួលខុសត្រូវ

អគ្គិសនីកម្ពុជាមានសិទ្ធិ និងការទទួលខុសត្រូវចំពោះការផលិត បញ្ជូន និងចែកចាយ ថាមពលអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមកាតព្វកិច្ចនៃការធ្វើពាណិជ្ជកម្មរបស់ខ្លួន ដែលមានចែងនៅក្នុងច្បាប់លក្ខន្តិកៈ អាជ្ញាប័ណ្ណ និងបទបញ្ញត្តិដទៃទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា។

អគ្គិសនីកម្ពុជា ប្រតិបត្តិជាសហគ្រាសពាណិជ្ជកម្មមួយ មានឯករាជ្យភាព ក្នុងការរៀបចំអាជីវកម្មរបស់ខ្លួនលើការផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនី និងបង្កើតទុនវិនិយោគ ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងមានការទទួលខុសត្រូវលើចំណូល ចំណាយ។

អគ្គិសនីកម្ពុជា ត្រូវអនុវត្តន៍តាមល័ក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណ ចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីផ្តល់សេវាកម្មអគ្គិសនី។ អគ្គិសនីកម្ពុជា ត្រូវអនុវត្តន៍ និងធ្វើឲ្យសម្រេចនូវផែនការអាជីវកម្មរបស់ខ្លួន ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជា និងអនុលោមតាមគោលនយោបាយថាមពលអគ្គិសនីជាតិ និងផែនការអភិវឌ្ឍន៍ជាតិ ។

អគ្គិសនីកម្ពុជា ត្រូវកំណត់សកម្មភាពអាជីវកម្ម ដែលមានចែងនៅក្នុងលក្ខន្តិកៈ និងអាជ្ញាប័ណ្ណដែលបានអនុម័តដោយអាជ្ញាធរអគ្គិសនីកម្ពុជា។

អគ្គិសនីកម្ពុជា ត្រូវបានអនុញ្ញាតលើការទទួលខុសត្រូវចំពោះ ៖

១ ការផលិត ការបញ្ជូន និងការបែងចែកថាមពលអគ្គិសនី ក្នុងគោលបំណង ដើម្បីឆ្លើយតបតាមតម្រូវការថាមពលរបស់អ្នកជាវគ្រប់ប្រភេទ។

២ ការនាំចូល និងនាំចេញ ថាមពលអគ្គិសនី ជាមួយប្រទេសជិតខាង ។

៣ ការសាងសង់ និងដាក់ឲ្យដំណើរការបណ្តាញជាតិបញ្ជូនអគ្គិសនី ដើម្បីធានានូវការផ្គត់ផ្គង់អគ្គិសនីឲ្យបានគ្រប់គ្រាន់ និងមានគុណភាព។

៤ ការសាងសង់ និងដាក់ឲ្យដំណើរការបណ្តាញបញ្ជូនរង ក្នុងគោលបំណង ចែកចាយអគ្គិសនី និងផ្គត់ផ្គង់ដល់តំបន់គ្រប់គ្រងដោយអគ្គិសនីកម្ពុជា និងតំបន់ដទៃទៀត។

៥ ការលក់ថាមពលអគ្គិសនី និងការបម្រើសេវាកម្មដែលពាក់ព័ន្ធ ។

៦ ការទិញថាមពល ការបញ្ជូនថាមពល និងការទិញ-លក់ថាមពល រវាងអគ្គិសនីកម្ពុជា និងដៃគូអ្នកផលិតថាមពលឯករាជ្យផ្សេងៗទៀត។

អគ្គិសនីកម្ពុជា បានប្រភពទុនមកពី ៖

១ ការផ្តល់ជំនួយពីរាជរដ្ឋាភិបាលកម្ពុជា ។

២ អចលនទ្រព្យនិងដីធ្លីទាំងឡាយ ដែលត្រូវបានផ្ទេរជូនអគ្គិសនីកម្ពុជា ដោយរាជរដ្ឋាភិបាល ដូចមាននៅក្នុងមាត្រាទី៧ នៃអនុក្រឹត្យ លេខ ២៣។

៣ ប្រាក់ចំណូល ដោយយោងតាមគោលការណ៍គណនេយ្យរបស់អគ្គិសនីកម្ពុជា ។

៤ ការផ្តល់ហិរញ្ញប្បទានឥតសំណង និងហិរញ្ញប្បទានឥណទានផ្សេងៗ ដែលអគ្គិសនីកម្ពុជាបានទទួលដោយមានការអនុម័តពីរាជរដ្ឋាភិបាល ។

៥ ការផ្តល់ឥណទានដល់អគ្គិសនីកម្ពុជាពីប្រភពហិរញ្ញវត្ថុផ្សេងៗ ដែលត្រូវអនុម័តដោយរាជរដ្ឋាភិបាល។

## ការវិវត្តន៍របស់អគ្គិសនីកម្ពុជា

ការប្រើប្រាស់អគ្គិសនី មានវត្តមាននៅប្រទេសកម្ពុជា ក្នុងឆ្នាំ១៩០៦ ។ មុនខែ តុលា ឆ្នាំ ១៩៥៨ ថាមពលអគ្គិសនី និងការប្រើប្រាស់សម្រាប់បំភ្លឺផ្សេងៗ នៅប្រទេសកម្ពុជា ត្រូវបានផ្គត់ផ្គង់ដោយក្រុមហ៊ុនឯកជនចំនួន ០៣ ៖

- ក្រុមហ៊ុនទឹក និងអគ្គិសនី ហៅកាត់ថា CEE
- សហព័ន្ធអគ្គិសនីឥណ្ឌូចិន ហៅកាត់ថា UNEDI
- ក្រុមហ៊ុនអគ្គិសនីបារាំង-ខ្មែរ ហៅកាត់ថា CFKE

ក្រុមហ៊ុនទឹក និងអគ្គិសនី (CEE) បានបម្រើសេវាអគ្គិសនីយ៉ាងធំនៅតំបន់ទីក្រុងភ្នំពេញ។ សហព័ន្ធអគ្គិសនីឥណ្ឌូចិន (UNEDI) ទទួលខុសត្រូវគ្រប់បណ្តាខេត្តផ្សេងៗទាំងអស់លើកលែងតែខេត្តបាត់ដំបង ដែលត្រូវបានផ្គត់ផ្គង់អគ្គិសនីដោយ ក្រុមហ៊ុនអគ្គិសនីបារាំង-ខ្មែរ (CFKE)។

យោងតាមក្រិតលេខៈ ៦៦៥-NS ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៥៨ ក្រុមហ៊ុនចំនួនពីរគឺ ក្រុមហ៊ុនទឹក និងអគ្គិសនី (CEE) និងសហព័ន្ធអគ្គិសនីឥណ្ឌូចិន (UNEDI) បានដាក់បញ្ចូលគ្នា ដោយដាក់ឈ្មោះថា **អគ្គិសនីកម្ពុជា** ។

អំឡុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៩ វិស័យថាមពលអគ្គិសនីនៅក្នុងប្រទេសបានឆ្លងកាត់ព្រឹត្តិការណ៍ចំនួនពីរដែលទទួលរងគ្រោះថ្នាក់ដោយសារ ៖សង្គ្រាមស៊ីវិល (ពីឆ្នាំ១៩៧០ - ១៩៧៥) និងមានភាពចលាចលជាប្រវត្តិសាស្ត្រ អំឡុងរបបខ្មែរក្រហម (ពីឆ្នាំ១៩៧៥ - ១៩៧៩)។ អំឡុងពេលនោះ មធ្យោបាយនៃការផលិត ការបញ្ជូន និងការចែកចាយ គ្រប់ប្រភេទទាំងអស់ត្រូវបានបំផ្លាញ មិនត្រឹមតែនៅរាជធានីភ្នំពេញទេ ប៉ុន្តែថែមទាំងនៅតំបន់ដទៃៗទៀតផងដែរ។

នៅឆ្នាំ១៩៧៩ អគ្គិសនីកម្ពុជា ត្រូវបានបង្កើតឡើងវិញ ដោយរចនាសម្ព័ន្ធរដ្ឋបាល ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម។ នៅឆ្នាំ ១៩៩១ អគ្គិសនីកម្ពុជា ត្រូវបានផ្ទេរឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់សាលារាជធានីភ្នំពេញ ដោយដាក់ឈ្មោះថា អគ្គិសនីភ្នំពេញ ហើយមានភារកិច្ចក្នុងការផ្គត់ផ្គង់អគ្គិសនីនៅរាជធានីភ្នំពេញ ទន្ទឹមនឹងនោះ ការផ្គត់ផ្គង់អគ្គិសនីនៅតាមបណ្តាខេត្តទាំងអស់ ត្រូវបានគ្រប់គ្រងដោយមន្ទីរឧស្សាហកម្មខេត្ត។

នៅឆ្នាំ ១៩៩២ អគ្គិសនីភ្នំពេញ ត្រូវបានផ្ទេរឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម ដោយប្តូរឈ្មោះជាថ្មីទៅជាអគ្គិសនីកម្ពុជាវិញ។ ក្រោយពីការបោះឆ្នោតជាសកលនៅឆ្នាំ១៩៩៣ អគ្គិសនីកម្ពុជា ត្រូវបានធ្វើកំណែទម្រង់ ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង រ៉ែ និងថាមពល ហើយទទួលខុសត្រូវសម្រាប់ការផ្គត់ផ្គង់ថាមពលអគ្គិសនីនៅរាជធានីភ្នំពេញ។ ចំណែកឯ អង្គភាពបម្រើសេវាកម្មថាមពល អគ្គិសនីនៅតាមបណ្តាខេត្តមួយចំនួន នៅតែស្ថិតក្រោមការគ្រប់គ្រង របស់អាជ្ញាធរខេត្ត ប៉ុន្តែទទួលការឧបត្ថម្ភថវិកាតាមរយៈក្រសួង រ៉ែ និងថាមពល។

នៅខែមីនា ឆ្នាំ១៩៩៦ តាមព្រះរាជក្រឹត្យលេខ ០៣៩៦/១០ អគ្គិសនីកម្ពុជា បានក្លាយជាក្រុមហ៊ុនស្វយ័តទទួលខុសត្រូវមានកំណត់មួយ ជាកម្មសិទ្ធិរបស់រដ្ឋទាំងមូល ដែលមានកាតព្វកិច្ចក្នុងការផលិត បញ្ជូន និងចែកចាយថាមពលអគ្គិសនីទូទាំងព្រះរាជាណាចក្រកម្ពុជា។ អគ្គិសនីកម្ពុជា ជាស្ថាប័នមួយស្របច្បាប់ ដោយមានស្វ័យភាពនៃការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុ។ អគ្គិសនីកម្ពុជា ទទួលខុសត្រូវចំពោះប្រាក់ចំណេញ ប្រាក់ខាតបង់ និងទទួលសងបំណុលទៅតាមទំហំនៃតម្លៃទ្រព្យសម្បត្តិរបស់ខ្លួន។

## រចនាសម្ព័ន្ធគ្រប់គ្រង

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ក្រសួង រ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺជាម្ចាស់សហាកម្មសិទ្ធិលើក្រុមហ៊ុនអគ្គិសនីកម្ពុជា។

## ក្រុមប្រឹក្សាភិបាល

ឆ្នាំ ២០១៤ ក្រុមប្រឹក្សានៃអគ្គិសនីកម្ពុជា មានសមាជិកចំនួន ០៧ រូប



**ឯកឧត្តម វិចឆ័រ ហ្សូនា**

ប្រធាន

តំណាង ក្រសួង រ៉ែ និងថាមពល



**ឯកឧត្តម កែវ រតនៈ**

សមាជិក

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា (ទីប្រឹក្សាផ្ទាល់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា)



**ឯកឧត្តម ចាន់ សុធី**

សមាជិក

តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



**ឯកឧត្តម ហែម គ្រាញ់ តូនី**

សមាជិក

តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី



**លោក ហង់ ទូច**

សមាជិក

តំណាង និយោជិតកម្មករ អគ្គិសនីកម្ពុជា



**លោក គូ ខែមលីន**
សមាជិក
តំណាង ក្រសួងយុត្តិធម៌



**លោកស្រី សុខ សុធាវី**
សមាជិក
តំណាង សភាពាណិជ្ជកម្មកម្ពុជា

## ការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា

អគ្គិសនីកម្ពុជា ត្រូវបានដឹកនាំដោយប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា ដោយមានឋានៈស្មើនឹងរដ្ឋលេខាធិការក្នុងជួររាជរដ្ឋាភិបាល ដែលជាអ្នករាយការណ៍ជូនក្រុមប្រឹក្សាភិបាល និងទទួលរបាយការណ៍ត្រឡប់មកវិញ ដើម្បីរាយការណ៍ជូនទៅ រដ្ឋមន្ត្រីក្រសួងអាណាព្យាបាលទាំងពីរ។ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា ត្រូវបានជួយការងារ ដោយអគ្គនាយករង ចំនួន ០៤ រូប និងនាយក ចំនួន ០៩ រូប ។ ឆ្នាំ ២០១៤ ថ្នាក់គ្រប់គ្រងរបស់អគ្គិសនីកម្ពុជា រួមមាន៖



**ឯកឧត្តម កែវ រតនៈ**
ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា
ទីប្រឹក្សាផ្ទាល់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា



**បណ្ឌិត ប្រាំង ចលសា**
អគ្គនាយករង
ផែនការ និងបច្ចេកទេស



**លោក ធឹង អ៊ឹង**
អគ្គនាយករង
ហិរញ្ញកិច្ច-អាជីវកម្ម



**ឯកឧត្តម អេង គន្ធា**
អគ្គនាយករង
រដ្ឋបាល



**លោក កែវ វីរៈ**
អគ្គនាយករង
មូលនិធិអគ្គិសនីតាវរូបនីយកម្មជនបទ



**លោក ជុន ពិសិដ្ឋ**

នាយក ផែនការយុទ្ធសាស្ត្រ និងគម្រោងការ



**កញ្ញា ស៊ិន សុវណ្ណានី**

នាយិកា ហិរញ្ញកិច្ច-គណនេយ្យ



**លោក លី ទីយ៉ា**

នាយក រដ្ឋបាល



**លោក ទូ សុខុន**

នាយក បញ្ជូនអគ្គិសនី



**លោក អួន ហេមរិទ្ធ**

នាយក ផលិតកម្ម



**លោក ជា ស៊ីនហ៊ើល**

នាយក អាជីវកម្ម-ចែកចាយ



**លោក ខ៉ែត សុខន**

នាយក លទ្ធកម្ម



**លោក អ៊ុំ ពិសិដ្ឋ**

នាយក វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី



**លោក ឿង កែវសិលា**

នាយក មូលនិធិអគ្គិសនីតាវ៉ូបនីយកម្មជនបទ

# អង្គការលេខ និងរចនាសម្ព័ន្ធគ្រប់គ្រង អគ្គិសនីកម្ពុជា



## ការអភិវឌ្ឍន៍ធនធានមនុស្ស

នៅឆ្នាំ ២០១៤ វិទ្យាស្ថានវិទ្យាសាស្ត្រអគ្គិសនី បានបណ្តុះបណ្តាលដល់សិក្ខាកាមជានិយោជិត មកពីនាយកដ្ឋាន និងអង្គភាពអគ្គិសនីខេត្ត-ក្រុងចំនួន ១.០០៧ នាក់ លើវគ្គជំនាញចំនួន ១៣២ វគ្គ និង ៨៥ មុខវិជ្ជា។ សិក្ខាកាមទាំងនោះ ត្រូវបានបណ្តុះបណ្តាលលើជំនាញផ្សេងៗគ្នា ក្នុងនោះរួមមាន៖ សិក្ខាកាម ២៥៤ នាក់ ខាងផ្នែកបណ្តាញចែកចាយ សិក្ខាកាម ៥៥ នាក់ ខាងផ្នែកប្រព័ន្ធការពាររោងចក្រផលិតអគ្គិសនី សិក្ខាកាម ១៦៩ នាក់ ខាងផ្នែកនាឡិកាស្ទង់ សិក្ខាកាម ២០៤ នាក់ ខាងផ្នែកសុវត្ថិភាពពលកម្ម សិក្ខាកាម ៨១ នាក់ ខាងផ្នែកផលិតថាមពល សិក្ខាកាម ១៤៧ នាក់ ខាងផ្នែកបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ សិក្ខាកាម ៥២ នាក់ ខាងផ្នែកកុំព្យូទ័រ និងសិក្ខាកាម ៤៥ នាក់ ខាងផ្នែកភាសាអង់គ្លេសបច្ចេកទេស ។

អគ្គិសនីកម្ពុជា ក៏បានសហការជាមួយស្ថាប័នជាតិ និងអន្តរជាតិដទៃទៀត ក្នុងការផ្តល់នូវវគ្គបណ្តុះបណ្តាលវិស័យថាមពលអគ្គិសនី ដើម្បីបង្កើនចំណេះដឹង និងបច្ចេកវិទ្យាថ្មីៗ ដល់និយោជិតរបស់ខ្លួន។

### តារាងទី ១ : និយោជិត-កម្មករ អគ្គិសនីកម្ពុជាពីឆ្នាំ ២០០៩ - ២០១៤

| ប្រភេទ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|---|
| បណ្ឌិត | ១ | ១ | ២ | ៣ | ៤ | ៤ |
| អនុបណ្ឌិត | ៩១ | ១០៤ | ១១៩ | ១៤២ | ១៨១ | ១៥១ |
| វិស្វករ និងបរិញ្ញាប័ត្រផ្សេងៗ | ៤៤៦ | ៥៥១ | ៦៧២ | ៨២២ | ៩៣៤ | ១,០៧៨ |
| បច្ចេកទេសជំនាញ | ៣៥៨ | ៣៩០ | ៤២៩ | ៤៩៣ | ៥៧០ | ៧៣៦ |
| កម្មករជំនាញ | ២៤៥ | ២៤៦ | ២០៧ | ១៨៨ | ១៨០ | ១៧៨ |
| ទុតិយភូមិ និង គ្មានជំនាញ | ១.២១៩ | ១.២៧៨ | ១.៣៣១ | ១.២៨៧ | ១.៣៩៨ | ១.៤៣៨ |
| សរុប | ២.៣៦០ | ២.៥៧០ | ២.៧៦០ | ២.៩៣៥ | ៣.២២៧ | ៣.៥៨៥ |

ចក្ខុវិស័យរបស់អគ្គិសនីកម្ពុជា សម្រាប់និយោជិតរបស់ខ្លួន គឺមានដូចខាងក្រោម ៖

- ផ្តល់ឲ្យនិយោជិតរបស់ខ្លួន មានឱកាស ដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈ ដោយផ្តោតលើសមត្ថភាពការងារ ភាពសុចរិត និងភាពស្មោះត្រង់ចំពោះអគ្គិសនីកម្ពុជា។
- ផ្តល់ឲ្យនិយោជិតរបស់ខ្លួន នូវស្ថានភាពជីវភាពរស់នៅបានល្អ និងសមរម្យ
- ធានានូវភាពត្រឹមត្រូវ ស្មើភាព និងផ្តល់ឱកាសដល់និយោជិតទាំងឡាយ ដើម្បីទទួលបាននូវការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍អគ្គិសនីកម្ពុជា។
- ផ្តល់ជូននូវល័ក្ខខ័ណ្ឌការងារល្អសមរម្យ ដោយបើកទូលាយក្នុងការប្រាស្រ័យទាក់ទងព័ត៌មាន ប្រកបដោយភាពស្មោះត្រង់ ក្នុងចំណោមនិយោជិតទាំងអស់ និងជួយជំរុញលើការចូលរួមធ្វើការជាក្រុមក្នុងគោលបំណងបង្កើនប្រសិទ្ធភាពការងារ ដោយផ្តោតលើទិសដៅស្ថាបនាក្រុមហ៊ុនឲ្យមានការរីកចម្រើន។

## ការនាំចូលអគ្គិសនីតង់ស្យុងខ្ពស់ពីប្រទេសថៃឡង់ដ៍ និងវៀតណាម

អគ្គិសនីកម្ពុជា បាននាំថាមពលអគ្គិសនីពីប្រទេសថៃឡង់ដ៍ តាមរយៈខ្សែបណ្តាញតង់ស្យុង ១១៥ kV តាមច្រកអារញ្ញប្រាថេតប្រទេសថៃឡង់ដ៍ មកខេត្តបន្ទាយមានជ័យនៃប្រទេសកម្ពុជា ដើម្បីផ្គត់ផ្គង់ដល់ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តសៀមរាប ចាប់ពីខែវិច្ឆិកា ឆ្នាំ ២០០៧ ។ អំឡុងឆ្នាំ ២០១៤ តាមខ្សែបណ្តាញខាងលើ អគ្គិសនីកម្ពុជា បាននាំថាមពលអគ្គិសនីបរិមាណ ៣៥០.០៧១.៦០០ kWh ពីប្រទេសថៃឡង់ដ៍។

ពីប្រទេសវៀតណាម តាមរយៈបណ្តាញខ្សែបញ្ជូនតង់ស្យុង ២៣០ kV ចំនួន ០២ សៀគ្វី អគ្គិសនីកម្ពុជា បាននាំថាមពលមកផ្គត់ផ្គង់នៅខេត្តតាកែវ នៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៩ និងរាជធានីភ្នំពេញ នៅថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០០៩ ។ តាមរយៈខ្សែបញ្ជូននេះ នៅឆ្នាំ២០១៣ អគ្គិសនីកម្ពុជា បាននាំថាមពលអគ្គិសនីមានបរិមាណ ៨៧៨.៥៣៣.២៤០ kWh។ បណ្តាញខ្សែបញ្ជូននេះ បានភ្ជាប់ទៅខ្សែបណ្តាញបញ្ជូន និងអនុស្ថានីយមួយចំនួនទៀត ដែលបានសាងសង់រួចពីខេត្តបាត់ដំបងមក ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង និងរាជធានីភ្នំពេញ ។ បណ្តាញនេះ នឹងត្រូវភ្ជាប់ជាមួយបណ្តាញបញ្ជូនមួយចំនួនទៀត ដែលកំពុងស្ថិតក្នុងការសាងសង់ ដូចជាបណ្តាញ ២៣០ kV ពីខេត្តតាកែវទៅខេត្តកំពត, បណ្តាញពីខេត្តកំពតទៅខេត្តព្រះសីហនុ និងបណ្តាញពីរាជធានីភ្នំពេញទៅខេត្តកំពង់ចាមជាដើម ហើយបណ្តាញខ្សែបញ្ជូនទាំងមូលនេះ នឹងក្លាយទៅជាបណ្តាញជាតិបញ្ជូន ។

## តម្រូវការថាមពល និងការផ្គត់ផ្គង់អគ្គិសនី នៅក្នុងតំបន់គ្រប់គ្រងដោយអគ្គិសនីកម្ពុជា

តំបន់ដែលគ្រប់គ្រងដោយអគ្គិសនីកម្ពុជា នៅឆ្នាំ២០១៤ មានចំនួន ១៥ តំបន់ ដែលស្ថិតនៅក្នុងខេត្ត-ក្រុងផ្សេងៗ ដូចមានខាងក្រោម៖

**អគ្គិសនីភ្នំពេញ (ប្រព័ន្ធភ្នំពេញ)** ភ្នំពេញ គឺជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងរបាយការណ៍នេះ ប្រព័ន្ធអគ្គិសនីភ្នំពេញ ផ្គត់ផ្គង់ពីអនុស្ថានីយទី១, អនុស្ថានីយទី២, អនុស្ថានីយទី៣, អនុស្ថានីយទី៤, អនុស្ថានីយទី៥, អនុស្ថានីយទី៦ និងអនុស្ថានីយទី៧ ដែលស្ថិតក្នុងការគ្រប់គ្រងរបស់អគ្គិសនីភ្នំពេញ រួមមានរាជធានីភ្នំពេញ តំបន់ជាយក្រុង ជុំវិញក្រុងភ្នំពេញ និងមានក្នុងទីប្រជុំជនខេត្តកណ្តាល។

ប្រព័ន្ធអគ្គិសនីភ្នំពេញ ត្រូវបានផ្គត់ផ្គង់ពីបណ្តាញជាតិបញ្ជូន រោងចក្រផលិតថាមពលឯករាជ្យ (IPPs) និងរោងចក្រអគ្គិសនីរបស់អគ្គិសនីកម្ពុជា ។ អានុភាពតម្លើងរបស់រោងចក្រផលិតថាមពលឯករាជ្យ (IPPs) គឺ ១.៤៨៣,៩០ MW អានុភាពនាំចូលពីប្រទេសវៀតណាមប្រមាណ ២០០ MW និងអានុភាពតម្លើងរបស់អគ្គិសនីកម្ពុជា (EDC) គឺមាន ៨៤ MW ដែលភាគច្រើនប្រើសម្រាប់បម្រុងទុក។

នៅឆ្នាំ២០១៤ តម្រូវការអានុភាពអតិបរមារបស់ប្រព័ន្ធភ្នំពេញគឺ ៥៦៣,៣៨ MW ។ ការជាវថាមពលពីការផលិតដោយរោងចក្រអគ្គិសនី ការនាំចូលមកប្រព័ន្ធអគ្គិសនីភ្នំពេញ និងទិញពីបណ្តាញជាតិបញ្ជូន បានកើនឡើងពី ៣.៣៩៨,១០ GWh ក្នុងឆ្នាំ ២០១៤ ទៅ ៤.២៦៨,៨៨ GWh ក្នុងឆ្នាំ២០១៤ ហើយការបាត់បង់ថាមពលនៅលើប្រព័ន្ធបានកើនឡើងពី ៨,២៣ % ក្នុងឆ្នាំ២០១៣ ទៅ ៩,៥៦% ក្នុងឆ្នាំ ២០១៤។

**អគ្គិសនីសៀមរាប** សៀមរាប គឺជាតំបន់ទាក់ទាញភ្ញៀវទេសចរណ៍ និងមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ការផ្គត់ផ្គង់អគ្គិសនីនៅខេត្តសៀមរាប បានមកពីការផលិត ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ខ្លួន និងនាំចូលថាមពលពីប្រទេសថៃឡង់ដ៍។

ប្រព័ន្ធអគ្គិសនីសៀមរាប សម្រាប់ឆ្នាំ២០១៤ មានសមត្ថភាពផ្គត់ផ្គង់ ៩០,៥០ MW និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៥៩,៣៩ MW ។ ប្រភពថាមពលនៅក្នុងប្រព័ន្ធទាំងមូល ទទួលបានពីបណ្តាញជាតិបញ្ជូន ការនាំចូលពីប្រទេសថៃឡង់ដ៍តាមរយៈអនុស្ថានីយ ១១៥/២២ kV និងការផលិតដោយរោងចក្រផ្ទាល់ខ្លួនសរុបប្រមាណ ៣៤៦,៥៦ GWh ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុង មធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៨០៨,០៨ km ដែលបានផ្គត់ផ្គង់ជូនអតិថិជនគ្រប់ប្រភេទចំនួន ៣៦.៦៩៤ ។

**អគ្គិសនីខេត្តព្រះសីហនុ** ខេត្តព្រះសីហនុ គឺជាតំបន់ទេសចរណ៍ ដែលមានឆ្នេរសមុទ្រស្អាតជាប់ចំណាត់ថ្នាក់លេខ ១ ស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា។ កន្លងមកប្រព័ន្ធអគ្គិសនីក្រុងព្រះសីហនុ ជាប្រព័ន្ធដាច់ដោយឡែកពីគេ និងទទួលការផ្គត់ផ្គង់ពីរោងចក្រអគ្គិសនីរបស់រោងចក្រផលិតថាមពលឯករាជ្យ និងរោងចក្រអគ្គិសនីកម្ពុជា ដែលមានអានុភាពសរុប ១៩,៦០ MW ។ ប៉ុន្តែក្នុងឆ្នាំ ២០១៤ ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ ប្រព័ន្ធអគ្គិសនីខេត្តព្រះសីហនុ ត្រូវបានភ្ជាប់ និងផ្គត់ផ្គង់មួយផ្នែកពីប្រព័ន្ធអគ្គិសនីកំពត ដែលបានទទួលថាមពលពីបណ្តាញជាតិបញ្ជូន និងការនាំចូលថាមពលពីប្រទេសវៀតណាមតាមរយៈបណ្តាញ ២២ kV ។

ខ្សែបណ្តាញនេះ បានធ្វើឲ្យអគ្គិសនីខេត្តព្រះសីហនុមានសមត្ថភាពផ្គត់ផ្គង់អគ្គិសនី ទៅអ្នកកាន់អាជ្ញាប័ណ្ណ និងតំបន់ជាច្រើនទៀតនៅក្រុងព្រះសីហនុ។ ថាមពលទិញសរុបប្រចាំឆ្នាំមាន ១៩៧,១៩ GWh ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២៩,៥០ MW ហើយប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៣៦២,១៦ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៤.២៣៨ ។

**អគ្គិសនីកំពង់ចាម** កំពង់ចាម ជាតំបន់ដែលសំបូរទៅដោយចំការកៅស៊ូ មានទីតាំងស្ថិតនៅភាគខាងកើតនៃប្រទេសកម្ពុជា។ ប្រព័ន្ធអគ្គិសនីកំពង់ចាម ត្រូវបានភ្ជាប់មកបណ្តាញជាតិបញ្ជូននៅឆ្នាំ២០១៣ ដែលទទួលថាមពលផ្គត់ផ្គង់ពីបណ្តាញជាតិ រោងចក្រផលិតថាមពលឯកជន និងមួយផ្នែកទៀត ត្រូវបានផ្គត់ផ្គង់ដោយប្រព័ន្ធអគ្គិសនី ដែលនាំចូលថាមពលពីប្រទេសវៀតណាម ។ ក្នុងឆ្នាំ២០១៤ ថាមពលទិញសរុបប្រចាំឆ្នាំ ៤៤,៨៦ GWh អានុភាពតម្លើង ៩,១៨ MW ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៣,៦០ MW ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៦៦៧,០៦ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៤.៨៧៦។

**សាខាមេមត់ និងពញាក្រែក** ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីសម្រាប់ស្រុកមេមត់ និងពញាក្រែក មានទីតាំងស្ថិតនៅខេត្តកំពង់ចាម និងប្រើប្រាស់ប្រព័ន្ធបណ្តាញតង់ស្យុងមធ្យម ២២ kV ។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីទៅតំបន់ទាំងពីរនេះ ត្រូវបាននាំចូលពីប្រទេសវៀតណាម ចាប់ពីឆ្នាំ២០០២ ដែលមានអានុភាពផ្គត់ផ្គង់តាមកិច្ចសន្យា ១០ MW ក្នុងឆ្នាំ ២០១៤ ថាមពលនាំចូលទទួលបាន ៤៦,១៣ GWh ព្រមទាំងប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ២៧៩,៤២ km ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៩,៨៩ MW និងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៨.៥៨៧ ។

**អគ្គិសនីបាត់ដំបង** បាត់ដំបង ជាតំបន់ដែលផលិតអង្ករជាប់ចំណាត់ថ្នាក់លេខ១ មានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា។ ខ្សែបញ្ជូន ១១៥ kV សម្រាប់នាំចូលថាមពលអគ្គិសនីពីប្រទេសថៃឡង់ដ៏ ត្រូវបានតភ្ជាប់ជាមួយប្រព័ន្ធបញ្ជូនអគ្គិសនីសៀមរាប និងបន្ទាយមានជ័យ ព្រមទាំងភ្ជាប់បន្តទៅបណ្តាញជាតិបញ្ជូនក្នុងឆ្នាំ២០១៣។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងខេត្តបាត់ដំបង បានមកពីការនាំចូលពីប្រទេសថៃឡង់ដ៏ ការផលិតថាមពលពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ និងការទិញថាមពលពីបណ្តាញជាតិបញ្ជូន។ ប្រព័ន្ធអគ្គិសនីបាត់ដំបង មានសមត្ថភាពផ្គត់ផ្គង់ ២១,៦០ MW និងមានថាមពលទិញសរុបប្រចាំឆ្នាំប្រមាណ ១៧០,០៣ GWh ព្រមទាំងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២៦,៤៩ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុង មធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៦៩០,៨៩ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៤២.៣៣៦ ។

**អគ្គិសនីបន្ទាយមានជ័យ និងសាខាមង្គលបុរី** បន្ទាយមានជ័យមានទីតាំងស្ថិតនៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ។ ការផ្គត់ផ្គង់ថាមពលអគ្គិសនីក្នុងខេត្តបន្ទាយមានជ័យ បានពីការនាំចូលពីប្រទេសថៃឡង់ដ៏ ការផលិតថាមពលពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ និងការទិញថាមពលពីបណ្តាញជាតិបញ្ជូន ។ សមត្ថភាពផ្គត់ផ្គង់របស់ប្រព័ន្ធអគ្គិសនីនេះមាន ២៣,០៤ MW ។ នៅឆ្នាំ ២០១៤ ថាមពលទិញសរុបគឺ ៧៥,៣០ GWh ដែលតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៩,៣៦ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ២៦៣,៤៦ km និងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៩.២១៧ ។

**អគ្គិសនីស្ទឹងត្រែង** ស្ទឹងត្រែង គឺជាខេត្តដាច់ស្រយាលមួយ និងមានប្រជាជនរស់នៅរង្វើលៗ ឃ្លាតៗពីគ្នាដែលស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា ។ ប្រព័ន្ធអគ្គិសនីក្រុងស្ទឹងត្រែង បានតភ្ជាប់ទៅប្រព័ន្ធអគ្គិសនីប្រទេសឡាវ តាមរយៈតង់ស្យុង ២២ kV តាំងពីឆ្នាំ ២០១០។ សមត្ថភាពផ្គត់ផ្គង់សរុបគឺ ៥,៦៤ MW ( ដែល ១,៦៤ MW ផ្គត់ផ្គង់ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ និង ៤ MW នាំចូលពីប្រទេសឡាវ ) ។ ក្នុងឆ្នាំ

២០១៤ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៤,៨៥ MW និងថាមពលផលិតសរុប ១៣,៩១ GWh ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ២៣៩,៥៧ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៥.៧៤២ ។

**អគ្គិសនីរតនគិរី** រតនគិរី ស្ថិតនៅជាប់ព្រំដែនខ្ពង់រាបកណ្តាល នៃប្រទេសវៀតណាម និងប្រទេសឡាវ។ ប្រព័ន្ធអគ្គិសនីរតនគិរី មានអានុភាពតម្លើង ៣,៦៨ MW ពីរោងចក្រវារីអគ្គិសនីរបស់អគ្គិសនីកម្ពុជាផ្ទាល់ និងផលិតករឯកជន ព្រមទាំង ៧,៥០ MW បាននាំចូលពីប្រទេសវៀតណាម តាមរយៈខ្សែបញ្ជូនរងតង់ស្យុង ៣៥ kV ។ នៅឆ្នាំ ២០១៤ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៥,៤០ MW ថាមពលផលិត និងនាំចូលសរុបប្រចាំឆ្នាំប្រមាណ ២៧,៩១ GWh ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១៤០,៧៥ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៤.៧២២។

**អគ្គិសនីតាកែវ និងសាខាអង្គតាសោម** តាកែវ មានទីតាំងស្ថិតនៅតំបន់វាលរាបភាគខាងត្បូងនៃប្រទេសកម្ពុជា។ ខ្សែបញ្ជូនតង់ស្យុង ២៣០ kV ចេញពីប្រទេសវៀតណាម និងអនុស្ថានីយតាកែវ ត្រូវបានដាក់ឲ្យដំណើរការនៅថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៩ ដើម្បីនាំចូលថាមពលពីប្រទេសវៀតណាម។ អគ្គិសនីតាកែវ មានរោងចក្រអគ្គិសនីរបស់ខ្លួនដើម្បីទុកបម្រុង ដែលមានអានុភាពតម្លើង ១,៥៦ MW និង ១៦ MW នាំចូលពីប្រទេសវៀតណាម ។ នៅឆ្នាំ២០១៤ តម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៨,២៦ MW ដែលប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៥៦៧,១២ km ថាមពលផលិតដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ ការនាំចូល និងទិញពីបណ្តាញជាតិបញ្ជូនសរុបប្រចាំឆ្នាំ ៥៧,៦៩ GWh ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៥.៦៣៦ ។

**អគ្គិសនីកំពត** កំពត មានទីតាំងស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា។ រោងចក្រអគ្គិសនីកំពត មានអានុភាពតម្លើង ៣,០៨ MW និងនាំចូលថាមពលពីប្រទេសវៀតណាម តាមរយៈខ្សែបណ្តាញតង់ស្យុង ២២ kV ឆ្លងកាត់កំពង់ត្រាច សម្រាប់ផ្គត់ផ្គង់ឲ្យក្រុងកំពត ។ នៅឆ្នាំ ២០១៤ ថាមពលផលិត ដែលផ្គត់ផ្គង់ដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ ការនាំចូល ការទិញពីបណ្តាញជាតិបញ្ជូនមានសរុប ៥៦,៩០ GWh ហើយតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៣,៣០ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៣៣៨,៨៩ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១១.២៣៤។

**សាខាកំពង់ត្រាច** ប្រព័ន្ធអគ្គិសនីកំពង់ត្រាច ស្ថិតនៅក្នុងខេត្តកំពត និងនាំចូលអគ្គិសនីពីប្រទេសវៀតណាមតាំងពីឆ្នាំ២០០២ ។ នៅឆ្នាំ២០១៤ អានុភាពជាវតាមកិច្ចសន្យាគឺ ១០ MW ហើយប្រវែងខ្សែបណ្តាញ ចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៧៥,៦៥ km មានថាមពលនាំចូលសរុប ១៣,២០ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ២,៩១ MW ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៣.៦៧០។

**អគ្គិសនីព្រៃវែង** ព្រៃវែង មានទីតាំងស្ថិតនៅភាគអាគ្នេយ៍ នៃប្រទេសកម្ពុជា។ ប្រព័ន្ធអគ្គិសនីក្រុងព្រៃវែងមានអានុភាពតម្លើងសរុប ៤,៩៤ MW ដែលបានមកពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ និងទទួលការផ្គត់ផ្គង់ពីខ្សែបណ្តាញអគ្គិសនី ដែលនាំចូលថាមពលពីប្រទេសវៀតណាម។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៧៤៩,៦៦ km និងតម្រូវការអានុភាពអតិបរមា ៨,០៧ MW ព្រមទាំងថាមពលផលិត និងនាំចូលក្នុងឆ្នាំ២០១៤ ប្រមាណ ២០,៩១ GWh ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៦.១១០ ។

**អគ្គិសនីស្វាយរៀង** ស្វាយរៀង មានទីតាំងស្ថិតនៅភាគអាគ្នេយ៍នៃប្រទេសកម្ពុជា។ អគ្គិសនីស្វាយរៀង ត្រូវបានផ្គត់ផ្គង់ដោយការនាំចូលថាមពលពីប្រទេសវៀតណាម និងពីរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់ អានុភាពផលិតសរុប ៨,៣០ MW ។ នៅឆ្នាំ ២០១៤ ថាមពលនាំចូល និងផលិតដោយរោងចក្រអគ្គិសនីកម្ពុជាផ្ទាល់គឺ ១៣៨,០៦ GWh ដែលមានតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៨ MW ។ ប្រវែងខ្សែបណ្តាញចែកចាយ

តង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៦០៤,៥៩ km ព្រមទាំងបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១៣.៨៩២។

**សាខាបាវិត** ប្រព័ន្ធអគ្គិសនីបាវិត ស្ថិតនៅខេត្តស្វាយរៀង និងទទួលការផ្គត់ផ្គង់ថាមពលតាមរយៈការនាំចូលពីប្រទេសវៀតណាម។ នៅឆ្នាំ២០១៤ អានុភាពនាំចូលពីប្រទេសវៀតណាមប្រមាណ ១៦ MW និងមានតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១៦,៩១ MW ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៣.៨០២ ។

**អគ្គិសនីមណ្ឌលគិរី** អគ្គិសនីមណ្ឌលគិរី ត្រូវបានផ្ទេរមកនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជានៅឆ្នាំ ២០១០។ អានុភាពតម្លើង ៣៧០ kW ផលិតដោយរោងចក្រវារីអគ្គិសនី អានុភាពផលិតដោយម៉ាស៊ីនឌីយ៉េស៊ែល ៣០០ kW និងអានុភាពនាំចូលពីប្រទេសវៀតណាមប្រមាណ ១ MW ។ ក្រោមការគ្រប់គ្រងរបស់ អគ្គិសនីកម្ពុជានៅឆ្នាំ២០១៤ ថាមពលផលិត និងនាំចូលសរុប ៤,៣០ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១,០១ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុង មធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១២៤,៥២ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ២.១៩៥។

**សាខាកែវសីមា** អគ្គិសនីកែវសីមា ស្ថិតនៅក្នុងខេត្តមណ្ឌលគិរី។ ការផ្គត់ផ្គង់ថាមពល គឺតាមរយៈការនាំចូលពីប្រទេសវៀតណាម ដែលអានុភាពបញ្ចេញតាមកិច្ចសន្យា ០,៣៦ MW ។ ថាមពលនាំចូលគឺ ៣,១៥ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ០,៧៤ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៨៨,៩០ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១.៥៥៤។

**អគ្គិសនីក្រចេះ** អគ្គិសនីក្រចេះ ត្រូវបានគ្រប់គ្រងដោយអគ្គិសនីកម្ពុជានៅឆ្នាំ ២០១១។ ប្រព័ន្ធអគ្គិសនីក្រចេះ ជាប្រព័ន្ធនៅដាច់ដោយឡែក ដែលផ្គត់ផ្គង់ដោយរោងចក្រផលិតថាមពលឯករាជ្យ ដែលមានអានុភាពតម្លើង ០,៥៥ MW ។ ក្រោមការគ្រប់គ្រងដោយអគ្គិសនីកម្ពុជានៅឆ្នាំ២០១៤ ថាមពលទិញ និងនាំចូលប្រចាំឆ្នាំប្រមាណ ១៦,២១ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ៣,១៥ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ១៦០,១៤ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ៤.៧៧៦។

**សាខាស្នួល** ប្រព័ន្ធអគ្គិសនីស្នួល ស្ថិតនៅខេត្តក្រចេះ ។ ប្រព័ន្ធនេះ បានផ្គត់ផ្គង់ដោយការនាំចូលថាមពលពីប្រទេសវៀតណាមប្រមាណ ៤ MW ដោយមានថាមពលផលិតប្រចាំឆ្នាំ ១០,៨១ GWh និងតម្រូវការប្រើប្រាស់អានុភាពជាអតិបរមា ១,៦៣ MW ។ ប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៣៣,៤៨ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១.២៣៨។

**អគ្គិសនីកំពង់ស្ពឺ** នៅពាក់កណ្តាលឆ្នាំ ២០១២ សាខាកំពង់ស្ពឺ ត្រូវបានបង្កើតជាអង្គភាពខេត្ត ខណៈដែលសាខានេះ កាលពីពេលកន្លងមក បានស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងអគ្គិសនីភ្នំពេញ។ អង្គភាពថ្មីនេះទទួលបន្ទុកគ្រប់គ្រងប្រព័ន្ធអគ្គិសនីក្នុងក្រុងកំពង់ស្ពឺ និងតំបន់តាមបណ្តោយផ្លូវជាតិលេខ៤ ដែលចែកចាយថាមពលដល់អនុស្ថានីយកំពង់ស្ពឺ។ ថាមពលដែលលក់ប្រចាំឆ្នាំគឺ ៨៣,៤៤ GWh មានប្រវែងខ្សែបណ្តាញចែកចាយតង់ស្យុងមធ្យម ២២ kV និងប្រវែងបណ្តាញតង់ស្យុងទាប ០,៤ kV មានប្រវែងសរុបចំនួន ៨២៥,៤៣ km ដែលបានផ្គត់ផ្គង់ដល់អតិថិជនគ្រប់ប្រភេទចំនួន ១១.១៥៩ ។

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW)

| ឆ្នាំ | | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|---|---|---|
| ទីតាំង | | អានុភាព | | | | | | |
| ភ្នំពេញ | | តម្លើង | ៤៥៣,៤៨ | ៤២៩,៤៨ | ៤២៩,៤៨ | ៦៣៣,៩០ | ១.២១៩,៥៨ | ១.៧២៧,៩០ |
| | | បញ្ចេញ | ៣១៧,៤៩ | ៣១៧,៤៩ | ៣៣២,៤៩ | ៥៧១,២៩ | ៩៦៨,១៩ | ១.៥៣២,៤៩ |
| អគ្គិសនីកម្ពុជា | | តម្លើង | ៤៥,៦០ | ៤៤ | ៤៤ | ៤៤ | ៤៤ | ៤៤ |
| | | បញ្ចេញ | ៤២,៦០ | ៤១ | ៤១ | ៤១ | ៤១ | ៤១ |
| CUPL | IPP | តម្លើង | ៣៧,១០ | ៣៧,១០ | ៣៧,១០ | ៣៧,១០ | ៣៧,១០ | ៣៧,១០ |
| | | បញ្ចេញ | ៣១,៩៩ | ៣១,៩៩ | ៣១,៩៩ | ៣១,៩៩ | ៣១,៩៩ | ៣៣,៥០ |
| គិរីរម្យ ១ | IPP | តម្លើង | ១២ | ១២ | ១២ | ១២ | ១២ | ១២ |
| | | បញ្ចេញ | ១១ | ១១ | ១១ | ១១ | ១១ | ១១ |
| គិរីរម្យ ៣ | IPP | តម្លើង | - | - | - | ១៨ | ១៨ | ១៨ |
| | | បញ្ចេញ | - | - | - | ១៨ | ១៨ | ១៨ |
| កំចាយ | IPP | តម្លើង | - | - | - | ១៩៤,១០ | ១៩៤,១០ | ១៩៤,១០ |
| | | បញ្ចេញ | - | - | - | ១៩៤,១០ | ១៩៤,១០ | ១៩៤,១០ |
| អាតៃ | IPP | តម្លើង | - | - | - | - | ១២០ | ១២០ |
| | | បញ្ចេញ | - | - | - | - | ១២០ | ១២០ |
| ឫស្សីជ្រុំក្រោម | IPP | តម្លើង | - | - | - | - | ៣៣៨ | ៣៣៨ |
| | | បញ្ចេញ | - | - | - | - | ១៦៩ | ៣៣៨ |
| តាតៃ | IPP | តម្លើង | - | - | - | - | - | ២៤៦ |
| | | បញ្ចេញ | - | - | - | - | - | ២៤៦ |
| CEL | IPP | តម្លើង | - | - | - | - | ១២០ | ១២០ |
| | | បញ្ចេញ | - | - | - | - | ១០០ | ១០០ |
| CIIDG | IPP | តម្លើង | - | - | - | - | - | ២៧០ |
| | | បញ្ចេញ | - | - | - | - | - | ១២៥.០៩ |
| KEP | IPP | តម្លើង | ៤៩,២០ | ៤៩,២០ | ៤៩,២០ | ៤៩,២០ | ៤៩,២០ | ៤៩,២០ |
| | | បញ្ចេញ | ៤៥ | ៤៥ | ៤៥ | ៤៣,២០ | ៤៣,២០ | ៤៣,២០ |
| CITY Power | IPP | តម្លើង | ៧,៦៨ | ៧,៦៨ | ៧,៦៨ | - | ៧,៦៨ | - |
| | | បញ្ចេញ | ៦,៩០ | ៦,៩០ | ៦,៩០ | - | ៦,៩០ | - |
| CEP | IPP | តម្លើង | ៤៩,២០ | ៤៩,២០ | ៤៩,២០ | ៤៩,២០ | ៤៩,២០ | ៤៩,២០ |
| | | បញ្ចេញ | ៤៥ | ៤៥ | ៤៥ | ៤៥ | ៤៥ | ៤៥ |
| COLBEN | IPP | តម្លើង | ២០,២០ | ២០,២០ | ២០,២០ | ២០,២០ | ២០,២០ | ២០,២០ |
| | | បញ្ចេញ | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| TH | IPP | តម្លើង | ១០ | - | - | - | - | - |
| | | បញ្ចេញ | ៨ | - | - | - | - | - |

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW) (ត)

| ឆ្នាំ | | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|---|---|---|
| ទីតាំង | | អានុភាព | | | | | | |
| COLBEN PPSEZ | IPP | តម្លើង | ១២,៤០ | - | - | - | - | - |
| | | បញ្ចេញ | ១០ | - | - | - | - | - |
| សុវណ្ណភូមិ | IPP | តម្លើង | ១០,១០ | ១០,១០ | ១០,១០ | ១០,១០ | ១០,១០ | ១០,១០ |
| | | បញ្ចេញ | ៧ | ៧ | ៧ | ៧ | ៨ | ៨ |
| West PP (នាំចូល VN) | IMP | PPA | ២០០ | ២០០ | ២០០ | ២០០ | ២០០ | ២០០ |
| | | បញ្ចេញ | ១០០ | ១២០ | ១៣៥ | ១៧០ | ១៧០ | ២០០ |
| អគ្គិសនី ខេត្ត-ក្រុង | | តម្លើង | ១៦៣,០៤ | ១៧៤,៦៧ | ១៨៧,០៩ | ២១៤,៧៩ | ២១៧,២៤ | ២៥៧,២៤ |
| | | បញ្ចេញ | ១៥៦,២៦ | ១៦៧,៨៩ | ១៧៨,៩៩ | ២០៦,៦៩ | ២០៩,៨៩ | ២៤៧,៨៩ |
| អគ្គិសនី សៀមរាប | IPP | តម្លើង | - | - | - | - | - | - |
| | | បញ្ចេញ | - | - | - | - | - | - |
| | EDC | តម្លើង | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ |
| | | បញ្ចេញ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ | ១០,៥០ |
| | IMP | PPA | ៨០ | ៨០ | ៨០ | ៨០ | ៨០ | ៨០ |
| | | បញ្ចេញ | ៨០ | ៨០ | ៨០ | ៨០ | ៨០ | ៨០ |
| អគ្គិសនី ខេត្តព្រះសីហនុ | EDC | តម្លើង | ៥,៦០ | ៥,៦០ | ៥,៦០ | ៥,៦០ | ៥,៦០ | ៥,៦០ |
| | | បញ្ចេញ | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| | IPP | តម្លើង | ១៤ | ១៤ | ១៤ | ១៤ | ១៤ | ១៤ |
| | | បញ្ចេញ | ១០ | ១០ | ១០ | ១០ | ១០ | ១០ |
| អគ្គិសនី កំពង់ចាម | IPP | តម្លើង | ៧,៦៨ | ៧,៦៨ | ៧,៦៨ | ៧,៦៨ | ៧,៦៨ | ៧,៦៨ |
| | | បញ្ចេញ | ៧ | ៧ | ៧ | ៧ | ៧ | ៥ |
| | IMP | PPA | - | - | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ |
| | | បញ្ចេញ | - | - | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ |
| សាខា ពញាក្រែក | IMP | តម្លើង | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| | | បញ្ចេញ | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| សាខា មេមត់ | IMP | តម្លើង | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| | | បញ្ចេញ | ៥ | ៥ | ៥ | ៥ | ៥ | ៥ |
| អគ្គិសនី តាកែវ | EDC | តម្លើង | ១,៥៦ | ១,៥៦ | ១,៥៦ | ១,៥៦ | ១,៥៦ | ១,៥៦ |
| | | បញ្ចេញ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ |
| | IMP | តម្លើង | ៣ | ៣ | ៤ | ១៦ | ១៦ | ១៦ |
| | | បញ្ចេញ | ៣ | ៣ | ៤ | ១៦ | ១៦ | ១៦ |

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW)(ត)

| ឆ្នាំ | | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|---|---|---|
| ទីតាំង | | អានុភាព | | | | | | |
| អគ្គិសនីបាត់ដំបង | EDC | តម្លើង | ១,៦០ | ៣,២០ | ៣,២០ | ៣,២០ | ១,៦០ | ១,៦០ |
| | | បញ្ចេញ | ០,៨០ | ២,៤០ | ២,៤០ | ២,៤០ | ១,៦០ | ១,៦០ |
| | IPP | តម្លើង | - | - | - | - | - | - |
| | | បញ្ចេញ | - | - | - | - | - | - |
| | IMP | PPA | ២០ | ២០ | ២០ | ២០ | ២០ | ២០ |
| | | បញ្ចេញ | ២០ | ២០ | ២០ | ២០ | ២០ | ២០ |
| អគ្គិសនីកំពត | EDC | តម្លើង | ៣,០៨ | ៣,០៨ | ៣,០៨ | ៣,០៨ | ៣,០៨ | ៣,០៨ |
| | | បញ្ចេញ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| សាខាកំពង់ត្រាច | IMP | តម្លើង | ៣ | ១០ | ១០ | ១០ | ១០ | ១០ |
| | | បញ្ចេញ | ៣ | ១០ | ១០ | ១០ | ១០ | ១០ |
| អគ្គិសនីព្រៃវែង | EDC | តម្លើង | ១,៦៤ | ១,៦៤ | ១,៦៤ | ១,៦៤ | ១,៦៤ | ១,៦៤ |
| | | បញ្ចេញ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ |
| | IMP | តម្លើង | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ | ៣,៣០ | ៣,៣០ |
| | | បញ្ចេញ | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ | ៣,៣០ | ៣,៣០ |
| អគ្គិសនីបន្ទាយមានជ័យ | EDC | តម្លើង | ៣,០៨ | ៣,០៨ | ៣,០៨ | ៣,០៨ | ៣,០៨ | ៣,០៨ |
| | | បញ្ចេញ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| | IMP | PPA | ២០ | ២០ | ២០ | ២០ | ២០ | ២០ |
| | | បញ្ចេញ | ២០ | ២០ | ២០ | ២០ | ២០ | ២០ |
| អគ្គិសនីស្ទឹងត្រែង | EDC | តម្លើង | ១,៦៤ | ១,៦៤ | ១,៦៤ | ១,៦៤ | ១,៦៤ | ១,៦៤ |
| | | បញ្ចេញ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ | ១,៥០ |
| | IMP | តម្លើង | - | ២ | ២ | ៤ | ៤ | ៤ |
| | | បញ្ចេញ | - | ២ | ២ | ៤ | ៤ | ៤ |
| អគ្គិសនីរតនគិរី | IPP | តម្លើង | ១,៦០ | ១,៦០ | ០,៨០ | - | - | ២,៧២ |
| | | បញ្ចេញ | ១,៤០ | ១,៤០ | ០,៨០ | - | - | ១,២០ |
| | EDC | តម្លើង | ០,៩៦ | ០,៩៦ | ០,៩៦ | ០,៩៦ | ០,៩៦ | ០,៩៦ |
| | | បញ្ចេញ | ០,៩៦ | ០,៩៦ | ០,៩៦ | ០,៩៦ | ០,៩៦ | ០,៩៦ |
| | IMP | តម្លើង | - | - | ៧ | ៧ | ៧,៥០ | ៧,៥០ |
| | | បញ្ចេញ | - | - | ៧ | ៧ | ៧,៥០ | ៧,៥០ |
| អគ្គិសនីស្វាយរៀង | EDC | តម្លើង | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ |
| | | បញ្ចេញ | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ | ០,៨០ |
| | IMP | តម្លើង | ៧,៥០ | ៧,៥០ | ៧,៥០ | ៧ | ៧,៥០ | ៧,៥០ |
| | | បញ្ចេញ | ៧,៥០ | ៧,៥០ | ៧,៥០ | ៧ | ៧,៥០ | ៧,៥០ |
| សាខាបាវិត | IMP | តម្លើង | ៥ | ៥ | ៥ | ១៦ | ១៦ | ១៦ |
| | | បញ្ចេញ | ៥ | ៥ | ៥ | ១៦ | ១៦ | ១៦ |

## តារាងទី ២ : អានុភាពតម្លើង និងអានុភាពបញ្ចេញពីប្រភពរោងចក្រ និងការនាំចូល (MW) (ត)

| ទីតាំង | | ឆ្នាំ / អានុភាព | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|---|---|---|
| អគ្គិសនីមណ្ឌលគិរី | EDC | តម្លើង | - | ០,៦៧ | ០,៦៧ | ០,៦៧ | ០,៦៧ | ០,៦៧ |
| | | បញ្ចេញ | - | ០,៦៧ | ០,៦៧ | ០,៦៧ | ០,៦៧ | ០,៦៧ |
| | IMP | តម្លើង | - | - | - | ១ | ១ | ១ |
| | | បញ្ចេញ | - | - | - | ១ | ១ | ១ |
| សាខាកែវសីមា | IMP | តម្លើង | - | ០,៣៦ | ០,៣៦ | ០,៣៦ | ០,៣៦ | ០,៣៦ |
| | | បញ្ចេញ | - | ០,៣៦ | ០,៣៦ | ០,៣៦ | ០,៣៦ | ០,៣៦ |
| អគ្គិសនីក្រចេះ | EDC | តម្លើង | - | - | - | - | ០,៥៥ | ០,៥៥ |
| | | បញ្ចេញ | - | - | - | - | ០,៥០ | ០,៥០ |
| | IPP | តម្លើង | - | - | ២,៧២ | ២,៧២ | ២,៧២ | - |
| | | បញ្ចេញ | - | - | ១,២០ | ១,២០ | ១,២០ | - |
| សាខាស្នួល | IMP | តម្លើង | - | - | ១ | ៤ | ៤ | ៤ |
| | | បញ្ចេញ | - | - | ១ | ៤ | ៤ | ៤ |
| សរុប | | តម្លើង | ៦១៦,៥២ | ៦០៤,១៥ | ៦១៦,៥៧ | ៨៤៨,៦៩ | ១៤.៣៦,៨២ | ១.៩៨៥,១៤ |
| | | បញ្ចេញ | ៤៧៣,៧៥ | ៤៨៥,៧៨ | ៥១១,៨៨ | ៧៧៧,៩៨ | ១.១៧៨,០៨ | ១.៧៨០,៧៨ |
| ជាភាគរយ , % | | | ៧៦,៨៤% | ៨០,៤១% | ៨៣,០២% | ៩១,៦៧% | ៨១,៩៩% | ៨៩,៧១% |




**រូបភាពទី ១ : អានុភាពតម្លើងនៅឆ្នាំ ២០១៤**




**រូបភាព : អានុភាពបញ្ចេញនៅឆ្នាំ ២០១៤**

## តារាងទី ៣ : ថាមពលផលិតពីប្រភពរោងចក្រ និងការនាំចូល (GWh)

| ឆ្នាំ / ទីតាំង | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|---|
| **បណ្តាញជាតិ** | **១.៦៩២,៥៤** | **២.០៩៨,២១** | **២.៣៨៩,៤២** | **៣.០៨១,៥០** | **៣.៤២២,៦៦** | **៤.២២៧,៩៥** |
| អគ្គិសនីកម្ពុជា | ៨២,៨៦ | ៣៣,០៨ | ៤៨,៥២ | ៥៨,២៨ | ៣៥,៨៦ | ២៦,១០ |
| CUPL | ១៨២,២២ | ១២០,២១ | ១៣៣,៨១ | ១៣២,១៤ | ៧៣,១៣ | ៣៥,១៤ |
| Jupiter | - | - | - | - | - | - |
| គិរីរម្យ ១ | ៤៤,៨១ | ២៤,២១ | ៣៨,២៥ | ២៩,២១ | ៤៤,៥៧ | ៣៩,៣៦ |
| កំចាយ | - | - | - | ៣៩៦,៣៨ | ៤៦៣,២៧ | ៤២៣,៥២ |
| គិរីរម្យ ៣ | - | - | - | ៨៦,៤០ | ៩០,៣៩ | ៧៩,៦២ |
| អាតៃ | - | - | - | - | ២៦៧,០៦ | ៣២៦,៦៧ |
| ឫស្សីជ្រុំក្រោម | - | - | - | - | ១៣៨,១៥ | ៨៦៥,៩៧ |
| តាតៃ | - | - | - | - | - | ១០៣,៧១ |
| T.H | ១៧,៣១ | - | - | - | - | - |
| KEP | ២៥៦,២៥ | ២៣០,៣៨ | ២៣១,៩០ | ១៩៦,៩៥ | ១៣៩,៦៧ | ៨០,១៣ |
| City Power | ៣៤,១១ | ១៨,២៣ | ២៥,២៦ | ១៥,៧៩ | ១៣,១៤ | - |
| CEP | ២៦៩,៤៨ | ២៤៧,២៩ | ២២៧,៧០ | ២០៩,៤៦ | ១៤៣,៧៣ | ៩៦,៣៥ |
| COLBEN | ៥៣,២៤ | ៣៥,៨០ | ៣៤,១៧ | ៣១,០៧ | ១៩,១៥ | ១១,១៦ |
| S.L Garment | ៥,៧៦ | ៤,០៥ | ១១,៨៦ | ១០,១៧ | ៥,៥២ | ១,៣៣ |
| COLBEN PPSEZ | ៤៥,០៦ | - | - | - | - | - |
| សុវណ្ណភូមិ | ២៨,០៣ | ៣២,០៧ | ៤៦,៥០ | ៣៧,៤២ | ២៩,៧៥ | ៤២,៦៣ |

## តារាងទី ៣ : ថាមពលផលិតពីប្រភពរោងចក្រ និងការនាំចូល (GWh) (ត)

| ឆ្នាំ / ទីតាំង | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|---|
| CEL | - | - | - | - | ១៣៩ | **៦៥៣,៨០** |
| CIIDG | - | - | - | - | - | **១៦៦,៥៩** |
| ថៃ | - | - | - | ៧៦,១៦ | ៤១៦,៩៧ | **៣៥០,០៧** |
| វៀតណាម | ៣៥៧,២១ | ៩៥៤,៥៥ | ១.១២០,៩៦ | ១.១៩៨,៩៦ | ១.៣២៩,១២ | **៨៧៨,៥៣** |
| PP Sugar | - | - | - | ១,៣២ | ០,៦៥ | **៩,៨៣** |
| សៀមរាប | ១៦៥,២០ | ១៩៣,៩៨ | ២១៤,១៥ | ២៦៨,៤៣ | ៤,៤០ | **៥,០៨** |
| ព្រះសីហនុ | ៥១,១៦ | ៦៤,៩៦ | ៧៦,២២ | ៩០,០២ | ២៥,៣៦ | **៩,១៧** |
| កំពង់ចាម | ២៥,២៧ | ៣៤,៩៥ | ៣៨,៤៦ | ៥៧,០៨ | ៣២,០៦ | **៨,០៤** |
| តាកែវ | ៧,៣៩ | ៩,២៨ | ១៣,១១ | ២៥,៧២ | ០,០៣ | **០,០២** |
| បាត់ដំបង | ៣៨,២៥ | ៤៩,៧៣ | ៦៧,៨៣ | ១០៥,៩៩ | ០,០១ | **០,០១** |
| កំពត | ១០,១៧ | ២០,៨២ | ៣២,៧៥ | ១៤,៤១ | ១១,៥១ | **១៥,០៩** |
| បន្ទាយមានជ័យ | ១៩,១៦ | ២៤,៦៣ | ២៨,៣៧ | ៤០,១៣ | ០,១៦ | **០,០៤** |
| **ក្រៅបណ្តាញជាតិ** | **១២៥,៣១** | **១៤៤,២៩** | **១៧៤,៦៥** | **២២៨,៥៤** | **២៦៦,៣៣** | **២៨៣,៨៤** |
| ពញាក្រែក | ២៦,៩២ | ២៥,៩៨ | ៣២,២៧ | ៣៩,៩៤ | ៣៩,១៨ | **៣០,៣២** |
| មេមត់ | ១០,៥៦ | ១០,៤០ | ១១,២៦ | ១៤,០៣ | ១៥,៦៧ | **១៥,៤០** |
| កំពង់ត្រាច | ៥,៣៩ | ៨,៦៨ | ១៤,៩២ | ១៧,០៥ | ១៦,៦៤ | **១៣,២០** |
| ព្រៃវែង | ៣,៣៦ | ៤,៦៨ | ៦,៦០ | ១១,៦៥ | ១៥,៣៨ | **១៣,៤៤** |
| ស្ទឹងត្រែង | ៤,៣៩ | ៥,៤០ | ៦,៦៥ | ៩,០១ | ១០,៥៨ | **១៣,៩១** |
| រតនគិរី | ៦,៤១ | ៨,១៩ | ៩,៤៧ | ១៧,១៦ | ២២,៧៣ | **២៧,៩១** |
| ស្វាយរៀង | ១២,៩១ | ១៨,១៥ | ២៣,៨០ | ២៦,៩៩ | ៣៣,២១ | **១៣៦,៧៤** |
| បាវិត | ៥៥,៣៧ | ៦០,៨៦ | ៥៩,៣៥ | ៧៤,០២ | ៨៧,៤៧ | **-** |
| មណ្ឌលគិរី | - | ១,១០ | ២,៣៤ | ២,៩៨ | ៣,៣៩ | **៤,៣០** |
| កែវសីមា | - | ០,៤៥ | ១,០៣ | ១,៤៨ | ២,២១ | **៣,១៥** |
| ក្រចេះ | - | - | ២,៣២ | ៦,៨៥ | ១០,៤៩ | **១៤,៨៦** |
| ស្ទូល | - | - | ៤,៦៤ | ៧,៣៨ | ៩,៣៥ | **១០,២០** |
| **សរុប** | **១.៨១៧,៨៥** | **២.២៤២,៤៩** | **២.៥៦៤,០៧** | **៣.៣១០,០៥** | **៣.៦៨៨,៩៩** | **៤.៥១១,៧៩** |

កំណត់សម្គាល់៖ ថាមពលផ្ទេរពីប្រតិបត្តិការរួមគ្នារវាងសាខា និងសាខាប្រមាណ ៩៣៨,៦២ GWh

## តារាងទី ៤ : ប្រភពថាមពលផលិតពីប្រភពរោងចក្រ និងការនាំចូលឆ្នាំ ២០១៤ (GWh)

| ទីតាំង | អគ្គិសនីកម្ពុជា | ឯកជន | ការនាំចូល | សរុប |
|---|---|---|---|---|
| បណ្ដាញជាតិ | ៣២,១៣ | ២.៩៥២,១៥ | ១.២៤៣,៦៧ | ៤.២២៧,៩៥ |
| ភ្នំពេញ | ២៦,១០ | ២.៩៣៥,៨០ | ១.២២៨,៦០ | ៤.១៩០,៥១ |
| សៀមរាប | ៥,០៨ | - | - | ៥,០៨ |
| ព្រះសីហនុ | ០,៨៦ | ៨,៣១ | - | ៩,១៧ |
| កំពង់ចាម | - | ៨,០៤ | - | ៨,០៤ |
| តាកែវ | ០,០២ | - | - | ០,០២ |
| បាត់ដំបង | ០,០១ | - | - | ០,០១ |
| កំពត | ០,០៣ | - | ១៥,០៧ | ១៥,០៩ |
| បន្ទាយមានជ័យ | ០,០៤ | - | - | ០,០៤ |
| ក្រៅបណ្ដាញ | ២,៥៨ | ១៣,៨០ | ២៦៧,៤៧ | ២៨៣,៨៤ |
| ពញាក្រែក | - | ០,១៥ | ៣០,១៧ | ៣០,៣២ |
| មេមត់ | - | - | ១៥,៨០ | ១៥,៨០ |
| កំពង់ត្រាច | - | - | ១៣,២០ | ១៣,២០ |
| ព្រៃវែង | ០,១៥ | ១៣,២៩ | - | ១៣,៤៤ |
| ស្ទឹងត្រែង | ០,១៤ | - | ១៣,៧៧ | ១៣,៩១ |
| រតនគិរី | ០,៥៣ | ០,០៦ | ២៧,៣១ | ២៧,៩១ |
| ស្វាយរៀង | ០,១១ | - | ១៣៦,៦៣ | ១៣៦,៧៤ |
| បាវិត | - | - | - | - |
| មណ្ឌលគិរី | ១,៦៥ | - | ២,៦៥ | ៤,៣០ |
| កែវសីមា | - | - | ៣,១៥ | ៣,១៥ |
| ក្រចេះ | ០,០០ | ០,២៩ | ១៤,៥៧ | ១៤,៨៦ |
| ស្នួល | - | - | ១០,២០ | ១០,២០ |
| សរុប | ៣៤,៧១ | ២.៩៦៥,៩៤ | ១.៥១១,១៤ | ៤.៥១១,៧៩ |




រូបភាពទី៣ : ថាមពលផលិតតាមប្រភេទ នៅឆ្នាំ ២០១៤

## តារាងទី ៥ : ការផលិតថាមពលតាមប្រភេទ អំឡុងឆ្នាំ ២០១៤ (GWh)

| ទីតាំង | ប្រេងឥន្ធនៈ | វារីអគ្គិសនី | ជីវម៉ាស់ | ធ្យូងថ្ម | នាំចូល | សរុប |
|---|---|---|---|---|---|---|
| បណ្តាញជាតិ | ២៦៤,៨៤ | ១.៨៣៨,៨៤ | ១១,១៦ | ៨៦៣,០២ | ១.២៥០,១០ | ៤.២២៧,៩៥ |
| ភ្នំពេញ | ២៤៨,៨៨ | ១.៨៣៨,៨៤ | ១១,១៦ | ៨៦៣,០២ | ១.២២៨,៦០ | ៤.១៩០,៥១ |
| សៀមរាប | ៥,០៨ | - | - | - | - | ៥,០៨ |
| ព្រះសីហនុ | ៩,១៧ | - | - | - | - | ៩,១៧ |
| កំពង់ចាម | ១,៦១ | - | - | - | ៦,៤២ | ៨,០៤ |
| តាកែវ | ០,០២ | - | - | - | - | ០,០២ |
| បាត់ដំបង | ០,០១ | - | - | - | - | ០,០១ |
| កំពត | ០,០៣ | - | - | - | ១៥,០៧ | ១៥,០៩ |
| បន្ទាយមានជ័យ | ០,០៤ | - | - | - | - | ០,០៤ |
| ក្រៅបណ្តាញ | ០,៨៥ | ២,០៨ | - | - | ២៨០,៩១ | ២៨៣,៨៤ |
| ពញាក្រែក | - | - | - | - | ៣០,៣២ | ៣០,៣២ |
| មេមត់ | - | - | - | - | ១៥,៨០ | ១៥,៨០ |
| កំពង់ត្រាច | - | - | - | - | ១៣,២០ | ១៣,២០ |
| ព្រៃវែង | ០,១៥ | - | - | - | ១៣,២៩ | ១៣,៤៤ |
| ស្ទឹងត្រែង | ០,១៤ | - | - | - | ១៣,៧៧ | ១៣,៩១ |
| រតនគិរី | ០,០៦ | ០,៥៣ | - | - | ២៧,៣១ | ២៧,៩១ |
| ស្វាយរៀង | ០,១១ | - | - | - | ១៣៦,៦៣ | ១៣៦,៧៤ |
| បាវិត | - | - | - | - | - | - |
| មណ្ឌលគិរី | ០,១១ | ១,៥៤ | - | - | ២,៦៥ | ៤,៣០ |
| កែវសីមា | - | - | - | - | ៣,១៥ | ៣,១៥ |
| ក្រចេះ | ០,២៩ | - | - | - | ១៤,៥៧ | ១៤,៨៦ |
| ស្នួល | - | - | - | - | ១០,២០ | ១០,២០ |
| សរុប | ២៦៥,៦៩ | ១.៨៤០,៩២ | ១១,១៦ | ៨៦៣,០២ | ១.៥៣១,០១ | ៤.៥១១,៧៩ |




រូបភាពទី៤ : ការផលិតថាមពលតាមប្រភេទ នៅឆ្នាំ២០១៤

## តារាងទី ៦ : ប្រភពថាមពលផលិតក្នុងប្រព័ន្ធរបស់អគ្គិសនីកម្ពុជា អំឡុងឆ្នាំ ២០១៤ (GWh)

| ទីតាំង | អគ្គិសនីកម្ពុជា | ឯកជន | ការនាំចូល | ប្រតិបត្តិការរួមគ្នារវាង សាខា និងសាខា | សរុប |
|---|---:|---:|---:|---:|---:|
| បណ្តាញជាតិ | ៣២,១៣ | ២.៩៥២,១៥ | ១.២៤៣,៦៧ | ៩២៨,២៨ | ៥.១៥៦,២៣ |
| ភ្នំពេញ | ២៦,១០ | ២.៩៣៥,៨០ | ១.២២៨,៦០ | ៧៨,៣៧ | ៤.២៦៨,៨៨ |
| សៀមរាប | ៥,០៨ | - | - | ៣៤១,៣៨ | ៣៤៦,៤៦ |
| ព្រះសីហនុ | ០,៨៦ | ៨,៣១ | - | ១៣៧,៦១ | ១៤៦,៧៨ |
| កំពង់ចាម | - | ៨,០៤ | - | ៣៦,១៥ | ៤៤,១៩ |
| តាកែវ | ០,០២ | - | - | ៥៧,៦៧ | ៥៧,៦៩ |
| បាត់ដំបង | ០,០១ | - | - | ១៧០,០២ | ១៧០,០៣ |
| កំពត | ០,០៣ | - | ១៥,០៧ | ៣១,៨០ | ៤៦,៩០ |
| បន្ទាយមានជ័យ | ០,០៤ | - | - | ៧៥,២៦ | ៧៥,៣០ |
| ក្រៅបណ្តាញ | ២,៥៨ | ១៣,៨០ | ២៦៧,៤៧ | ១០,៣៥ | ២៩៤,១៩ |
| ពញាក្រែក | - | ០,១៥ | ៣០,១៧ | - | ៣០,៣២ |
| មេមត់ | - | - | ១៥,៨០ | - | ១៥,៨០ |
| កំពង់ត្រាច | - | - | ១៣,២០ | - | ១៣,២០ |
| ព្រៃវែង | ០,១៥ | ១៣,២៩ | - | ៧,៤៧ | ២០,៩១ |
| ស្ទឹងត្រែង | ០,១៤ | - | ១៣,៧៧ | - | ១៣,៩១ |
| រតនគិរី | ០,៥៣ | ០,០៦ | ២៧,៣១ | - | ២៧,៩១ |
| ស្វាយរៀង | ០,១១ | - | ១៣៦,៦៣ | ១,៣១ | ១៣៨,០៦ |
| បាវិត | - | - | - | - | - |
| មណ្ឌលគិរី | ១,៦៥ | - | ២,៦៥ | - | ៤,៣០ |
| កែវសីមា | - | - | ៣,១៥ | - | ៣,១៥ |
| ក្រចេះ | ០,០០ | ០,២៩ | ១៤,៥៧ | ១,៣៦ | ១៦,២១ |
| ស្នួល | - | - | ១០,២០ | ០,២១ | ១០,៤១ |
| សរុប | ៣៤,៧១ | ២.៩៦៥,៩៤ | ១.៥១១,១៤ | ៩៣៨,៦២ | ៥.៤៥០,៤១ |

## តារាងទី ៧ : អានុភាពអតិបរមាប្រចាំឆ្នាំ (MW)

| ទីតាំង | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|---|
| ភ្នំពេញ | ២៤៤,១០ | ៣០០,២០ | ៣៤៩,៤០ | ៤១០ | ៤៩២,៥០ | ៥៦៣,៣៨ |
| សៀមរាប | ២៩,៩៨ | ៣៤,៩៧ | ៣៩,០៧ | ៤៧,៣៦ | ៥៦,៧០ | ៥៩,៣៩ |
| ព្រះសីហនុ | ១០,១៧ | ១៣,៤០ | ១៦,៤០ | ១៨,៥០ | ២៤,៨០ | ២៩,៥០ |
| កំពង់ចាម | ៦,៨០ | ៧,៣០ | ៨,៤៥ | ១០,៤៥ | ១៦,៨០ | ១៣,៦០ |
| ពញាក្រែក | ៥,៥០ | ៥ | ៦,៥០ | ៦,៥០ | ៦,៥០ | ៦ |
| មេមត់ | ៣ | ៣ | ៣,៩៤ | ៣,៩៤ | ៤,៥០ | ៣,៨៩ |
| តាកែវ | ២,២៦ | ២,៦៨ | ៤,៧៣ | ៦,៧០ | ៨,៧៧ | ១៨,២៦ |
| បាត់ដំបង | ៧,៩៨ | ១០,៤៥ | ១៦,៧៧ | ២០,៥៣ | ២២,៧៨ | ២៦,៤៩ |
| កំពត | ២,៣៦ | ៤,៥២ | ៥,៤៧ | ៥,៣៤ | ៥,៩០ | ១៣,៣០ |
| កំពង់ត្រាច | ១,២០ | ២,១៣ | ២,៣៨ | ៣,១០ | ៣,៣៨ | ២,៩១ |
| ព្រៃវែង | ០,៧៩ | ០,៩៣ | ១,៤៦ | ៣,១៥ | ២,៧៣ | ៨,០៧ |
| បន្ទាយមានជ័យ | ៤,៣២ | ៥,៥១ | ៦,២៨ | ៨,៨២ | ១០,៨០ | ១៩,៣៦ |
| ស្ទឹងត្រែង | ១,០៨ | ១,៩៦ | ២,៣៧ | ៣,២២ | ៣,៨០ | ៤,៨៥ |
| រតនគិរី | ១,៧៨ | ១,៩៤ | ២,២៤ | ៣,៦៩ | ៤,២០ | ៥,៤០ |
| ស្វាយរៀង | ២,៨០ | ៣,៧០ | ៥,៤០ | ៥,៣០ | ៦,៦៧ | ៨ |
| បាវិត | ៩,៥០ | ១១ | ១១,២០ | ១៥,១០ | ១៥,៦០ | ១៦,៩១ |
| មណ្ឌលគិរី | - | ០,៤៦ | ០,៦២ | ០,៧០ | ០,៨៦ | ១,០១ |
| កែវសីមា | - | - | - | ០,៣៨ | ០,៤៧ | ០,៧៤ |
| ក្រចេះ | - | - | ២,០៨ | ១,១៨ | ២,៤៨ | ៣,១៥ |
| ស្នួល | - | - | - | ១,៤៥ | ១,៤៨ | ១,៦៣ |
| សរុប | ៣៣៣,៦២ | ៤០៩,១៤ | ៤៨៤,៧៦ | ៥៧៥,៤១ | ៦៩១,៧២ | ៨០៥,៨៤ |




**រូបភាពទី៥ : ថាមពលផលិត, វិក្កយបត្រ និងប្រើប្រាស់ផ្ទាល់ខ្លួន សម្រាប់ប្រព័ន្ធអគ្គិសនីភ្នំពេញ ពីឆ្នាំ២០០៩ - ២០១៤**

## តារាងទី ៨ : ថាមពលលក់ (GWh)

| ទីតាំង | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ |
|---|---|---|---|---|---|---|
| ភ្នំពេញ | ១.២៤៦,៥៣ | ១.៥៤០,២៥ | ១.៧៥២,៤០ | ២.២៦៥,៨៤ | ២.៥៣០,៥១ | ២.៩៥៥,៦១ |
| សៀមរាប | ១៤៥,១២ | ១៧០,៩៧ | ១៨៨,២៦ | ២៣៧,៣០ | ២៧០,០៤ | ៣១៩,៣៣ |
